00428843

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

លេខ / No: D.250/3/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

Kingdom of Cambodia
Nation Religion King

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 01 / 2010
ម៉ោង (Time/Heure): 9:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

លេខសំណុំរឿង: ០០២/១៩-០៩-២០០៧-អ.វ.ត.ក.-ក.ស.ច.ស.

ចំពោះមុខ ៖ ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE (ម៉ាសែល ឡឺម៉ុង)

កាលបរិច្ឆេទ៖ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០

ភាសាដើម៖ ខ្មែរ /អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

---

## ដីកាសម្រេចរួមលើសំណើសុំបំពេញកិច្ចស៊ើបសួរពីរ របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងខ្មែរក្រោម និងការសម្លាប់ខ្ទាលនៅស្រុកបាកាន(ខេត្តពោធិ៍សាត់) ព្រមទាំងសំណើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើខ្មែរក្រោម និងលើជនជាតិវៀតណាម

---

**សហព្រះរាជអាជ្ញា**

អ្នកស្រី ជា លាង

លោក William SMITH

**ជនត្រូវចោទ**

នួន ជា | ខៀវ សំផន

អៀង សារី | កាំង ហ្គេកអ៊ាវ

អៀង ធីរិទ្ធ | ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

នី ច័ន្ទឌី ឡោ ឈុនធី | Elizabeth Rabesandratana
| Pierre-Olivier SUR
គង់ ពិសី ហុង គឹមសួន | Mahdev MOHAN
| Olivier BAHOUGNE
យុង ផានិត គីម ម៉េងឃី | David BLACKMAN
| Martine JACQUIN
ម៉ុច សុវណ្ណារី ស៊ីន សុវន | Annie DELAHAIE
| Fabienne TRUSSES-NAPROUS
ជេត វណ្ណលី ពេជ អង្គ | Patrick BAUDOIN
Silke STUDZINSKY | Lyma Thuy Nguyen
Phillipe CANONNE | Marie Guiraud

**មេធាវីការពារក្តី**

សុន អរុណ Michiel PESTMAN

អាង ឧត្តម Michael G.KARNAVAS

ផាត់ ពៅស៊ាង Diana ELLIS

ស សូវ៉ាន Jacques VERGES

ការ សាវុត្ថ François ROUX

Marie-Paule CANIZARES



CO-INVESTIGATING JUDGES · C.C.C. * C.E.T.

យើង **យូ ប៊ុនឡេង** និង Marcel LEMONDE (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក")

បានឃើញការស៊ើបសួរលើឈ្មោះ នួន ជា និង **ជនផ្សេងទៀត** ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យលើ**បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការវាយប្រហារលើសាសនា** បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២០៩ មាត្រា ២១០ មាត្រា ៥០០ មាត្រា ៥០១ មាត្រា ៥០៣ ដល់មាត្រា ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦

បានឃើញវិធាន៥៣ វិធាន៥៥(២) និង៥៥(១០) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. ("វិធានផ្ទៃក្នុង")

បានឃើញសំណើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើខ្មែរក្រោម និងលើជនជាតិវៀតណាម ចុះថ្ងៃ ០៣ ធ្នូ ២០០៩ (D250/3)

បានឃើញសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅស្រុកបាកាន (ខេត្តពោធិ៍សាត់) របស់សហព្រះរាជអាជ្ញា ចុះថ្ងៃ ១១ ធ្នូ ២០០៩ (D274)

បានឃើញសំណើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងខ្មែរក្រោម ចុះថ្ងៃ ០៦ មករា ២០១០ (D274/2)

00428845



បានឃើញដីកាសម្រេចទាក់ទងនឹងការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសំណើសុំលេខ D250/3 (D250/3/2)

**ការរំលឹកឡើងវិញអំពីនីតិវិធី**

១. នៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដើមបណ្តឹងរដ្ឋប្បវេណីមួយក្រុម[1] បានស្នើឲ្យសហចៅក្រមស៊ើបអង្កេត "ពិចារណាលើភស្តុតាងថ្មីទាក់ទងនឹងឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តលើក្រុមជនជាតិភាគតិចខ្មែរក្រោមនៅក្នុងខេត្តពោធិ៍សាត់ និងខេត្តតាកែវក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងធ្វើការបន្ថែមការចោទប្រកាន់ ដែលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ទាក់ទងនឹងប្រព្រឹត្តកម្មលើជនជាតិវៀតណាម[2]"។ នៅក្នុងសំណើសុំនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ជនល្មើសអាចនឹងចាត់ទុកជាអត្តនោម័តថា ខ្មែរក្រោមគឺជាជនជាតិវៀតណាម ដូច្នេះខ្មែរក្រោមត្រូវបានរាប់បញ្ចូលទៅក្នុងក្រុមជាតិវៀតណាម[3]។

២. នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៩ នៅក្រោមបញ្ញត្តិនៃវិធាន ៥៥(១០) ការិយាល័យសហព្រះរាជអាជ្ញា "ក.ស.ព." បានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយ ដែលមានគោលដៅប្រព្រឹត្តលើប្រជាជនខ្មែរក្រោម ក្នុងក្របខណ្ឌនៃគោលនយោបាយកំទេចជនជាតិវៀតណាមនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់[4]។

៣. នៅថ្ងៃទី ០៦ មករា ២០១០ នៅក្រោមបញ្ញត្តិនៃវិធាន ៥៥(១០) ក.ស.ព. បានដាក់សំណើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរមួយចំនួន ទាក់ទងនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តលើខ្មែរក្រោមនៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់[5]។

---

[1] លទ្ធភាពនៃការទទួលយកសំណើសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលសហចៅក្រមស៊ើបអង្កេតបានទទួលទាក់ទងនឹងឯកសារនេះ ត្រូវបានឆ្លើយតបនៅក្នុងដីកាដោយឡែកផ្សេងមួយទៀត ដែលបានលើកឡើងអំពីបញ្ហាទាក់ទងនឹងការស្នើសុំវិធានការការពារ នៅក្នុងផ្នែក VI នៃឯកសារនេះ។

[2] D250/3 កថាខណ្ឌ ០១

[3] D250/3 កថាខណ្ឌ ១១-១២

[4] D274 កថាខណ្ឌ ៣-៦

[5] D274/2 កថាខណ្ឌ ២-៥

00428846



**សំអាងហេតុនៃសេចក្តីសម្រេច**

៤. អនុលោមតាមវិធាន ៥៣ និង ៥៥(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក. វិសាលភាពនៃការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតត្រូវបានកម្រិតត្រឹមតែអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ លើសពីនេះ ស្របតាមចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៣ សីហា ២០០៨ ទាក់ទងនឹងការបំភ្លឺអំពីវិសាលភាពនៃកិច្ចស៊ើបសួរ[6] សហចៅក្រមស៊ើបអង្កេតអាចធ្វើការស៊ើបអង្កេតកាលៈទេសៈនៃអង្គហេតុនានាទាំងឡាយដែលសហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្ដឹងបាន លុះត្រាណាតែកាលៈទេសៈនៃអង្គហេតុនោះរួមចំណែកនៅក្នុងការបង្ហាញអំពីធាតុផ្សំយុត្តាធិការនៃបទល្មើស និង ទម្រង់នៃការទទួលខុសត្រូវណាមួយរបស់ជនត្រូវចោទ ។

៥. ក្រៅអំពីគោលបំណងជាក់លាក់ទាំងពីរខាងលើនេះ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតឲ្យធ្វើការស៊ើបសួរលើអង្គហេតុ ដែលមិនត្រូវបានប្ដឹងមកត្រឹមត្រូវស្របទៅតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងវិធាន ៥៣ និង ៥៥(៣) នៃវិធានផ្ទៃក្នុងនោះទេ។

៦. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា វិធាន ៥៣(១) មានចែងអំពីលក្ខខណ្ឌទំរង់មួយចំនួនដែលកំណត់អំពីសុពលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ លក្ខខណ្ឌទំរង់ទាំងអស់នេះក៏ត្រូវអនុវត្តផងដែរចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ជាងនេះទៅទៀត អនុលោមតាមមាត្រា ៣-២ (ជ) នៃសេចក្តីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ ឯកសារដែលមានបំណងចង់ដាក់ក្នុងលក្ខណៈជា ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ត្រូវដាក់ចំណងជើងឲ្យបានច្បាស់ថាជាដីកាទាំងនោះ។

៧. ឯកសារដែលដាក់ដោយ ក.ស.ព. នៅថ្ងៃ ១១ ធ្នូ ២០០៩ មានឈ្មោះថា "សំណើសុំបំពេញកិច្ចស៊ើបសួរ" នៅក្រោមបញ្ញត្តិនៃវិធាន ៥៥(១០)។ ប៉ុន្តែ ឯកសារនេះបានលើកឡើងអំពីអង្គហេតុ ដែលមិនត្រូវបានប្ដឹងពីមុនមកសហចៅក្រមស៊ើបអង្កេត ដូច្នេះសហចៅក្រមស៊ើបអង្កេត

---

[6] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសហចៅក្រមស៊ើបអង្កេត ដែលស្នើសុំឲ្យបញ្ជាក់អំពីវិសាលភាពនៃកិច្ចស៊ើបសួរដែលបានស្នើឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃ ១៣ សីហា ២០០៨ D98/I។

មិនអាចស៊ើបអង្កេតលើអង្គហេតុទាំងនេះបាននោះទេ[7]៖ ជាក់ស្តែង អនុលោមតាម កថាខណ្ឌ ៦៩ និងកថាខណ្ឌ ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេតត្រូវបានប្តឹងអំពីប្រព្រឹត្តកម្មលើជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង ខេត្តស្វាយរៀង និងក្នុងអំឡុងពេលដែលមានការឈ្លានពានចូលក្នុងទឹកដីវៀតណាមប៉ុណ្ណោះ ផ្ទុយទៅវិញសហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តលើខ្មែរក្រោមនៅក្នុងស្រុកបាកានខេត្តពោធិ៍សាត់នោះទេ។ ទោះបីជាសំណើសុំបានលើកឡើងអំពីវិធាន ៥៣ នៃវិធានផ្ទៃក្នុង ទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ[8] ក៏សំណើសុំនេះមិនបានបំពេញតាមលក្ខខណ្ឌនៃវិធាន ៥៣ វិធាន ៥៥-២ និងវិធាន ៥៥-៣ នោះដែរ ហើយដូច្នេះ មិនអាចត្រូវបានចាត់ទុកថាជា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមនោះទេ។ ដូច្នេះ សំណើសុំនេះគួរត្រូវបដិសេធចោល។

៨. ឯកសាររបស់ ក.ស.ព. ចុះថ្ងៃ ០៦ មករា ២០១០ ត្រូវបានធ្វើឡើងដើម្បី *"បញ្ជាក់អំពីកិច្ចស៊ើបសួរបន្ថែម ដែលសហព្រះរាជអាជ្ញាយល់ថាចាំបាច់ ទាក់ទងនឹងបញ្ហាជាក់ស្តែងដែលបានលើកឡើងនៅក្នុងឯកសាររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃ ១១ ធ្នូ ២០០៩ ទាក់ទងនឹងខ្មែរក្រោម និងការសម្លាប់រង្គាលនៅក្នុងស្រុកបាកាន[9]"*។ យ៉ាងណាមិញ យោងតាមហេតុផលដែលមានបញ្ជាក់ខាងលើ ឯកសារថ្ងៃ ១១ ធ្នូ ២០០៩ មានលើកឡើងអំពីអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតមិនត្រូវបានប្តឹងមក។ ដោយហេតុថា ឯកសារថ្ងៃ ០៦ មករា ២០១០ បានស្នើសុំការបំពេញកិច្ចស៊ើបសួរដែលមិនឋិតនៅក្នុងក្របខណ្ឌនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ សំណើសុំនេះគួរត្រូវបដិសេធចោល។

៩. ទាក់ទងទៅនឹងទិដ្ឋភាពទីមួយនៃសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ស្នើសុំឱ្យមានការពិចារណាលើភស្តុតាងថ្មីទាក់ទងនឹងឧក្រិដ្ឋកម្មប្រព្រឹត្តលើក្រុមខ្មែរក្រោម នៅក្នុងខេត្ត ពោធិ៍សាត់ និងខេត្តតាកែវ) សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញថា វាបានលើកឡើងនូវបញ្ហាដែលដូចគ្នាទៅនឹងសំណើសុំរបស់ ក.ស.ព. ជាក់ស្តែង អំពីការស៊ើបអង្កេតទាក់ទងនឹងប្រព្រឹត្តកម្មលើខ្មែរក្រោម និងជនជាតិវៀតណាមនៅតាមតំបន់ភូមិសាស្ត្រ ដែលមិនឋិតនៅក្នុងវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ដូច្នេះ

---

[7] D274 កថាខណ្ឌ ៣-៦

[8] D274 កថាខណ្ឌ ១

[9] D274/2 កថាខណ្ឌ ១

សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធចំពោះការលើកឡើងរបស់ដើម បណ្តឹងរដ្ឋប្បវេណី អំពីបញ្ហានេះ ក្នុងហេតុផលដូចការបដិសេធសំណើសុំរបស់ ក.ស.ព.។

១០. ពាក់ព័ន្ធនឹងទិដ្ឋភាពទីពីរនៃសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី (ការចោទប្រកាន់ដែលទាក់ទងនឹងបញ្ហាដែលថា ជនល្មើសអាចនឹងចាត់ទុកជាអត្តនោម័តថា ខ្មែរក្រោមគឺជាជនជាតិវៀតណាម) សហចៅក្រមស៊ើបអង្កេតនឹងមិនធ្វើការបញ្ជាក់អំពីការសម្រេចចិត្តទាក់ទងនឹងច្បាប់ដែលត្រូវអនុវត្តនោះទេ ព្រោះការកំណត់បទល្មើសបែបនេះនឹងត្រូវបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ស្របទៅតាមបញ្ញត្តិនៃវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង។ ដូច្នេះ ចំពោះបញ្ហាដែលទាក់ទងនឹងការសម្រេចថាជនរងគ្រោះឋិតនៅក្នុងក្រុមជាតិសាសន៍ណាមួយ ត្រូវធ្វើជាអត្តនោម័ត ឬជាសត្យានុម័តនោះ មិនអាចធ្វើបាននៅត្រឹមដំណាក់កាលនេះទេ ទោះបីជាសហចៅក្រមស៊ើបអង្កេតដឹងច្បាស់ណាស់ថា យោងទៅលើកថាខណ្ឌ ៦៩ និង ៧០ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេតទទួលបានបណ្តឹងអំពីអង្គហេតុ ទាក់ទងនឹងប្រព្រឹត្តកម្មលើជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង ខេត្តស្វាយរៀង និងក្នុងពេលដែលមានជម្លោះប្រដាប់អាវុធចូលក្នុងទឹកដីវៀតណាម។

១១. បន្ថែមលើនេះ នៅក្នុងអំឡុងពេលដំណើរការកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ថា ជនរងគ្រោះខ្មែរក្រោមត្រូវបានស្តាប់ចម្លើយក្នុងនាមជាសាក្សី ពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលទាក់ទងនឹងអង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ក្រៅពីការជួយដល់ការងារស៊ើបអង្កេតនៅទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ សហចៅក្រមស៊ើបអង្កេតអាចបញ្ជាក់បានថា ការស៊ើបអង្កេតលើខ្មែរក្រោមក្នុងលក្ខណៈជាក្រុម ក៏ពាក់ព័ន្ធផងដែរដល់ការកំណត់អំពីធាតុផ្សំយុត្តាធិការនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងទំរង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលត្រូវអនុវត្តចំពោះជនត្រូវចោទ[10]។

[10] ជាក់ស្តែង សហចៅក្រមស៊ើបអង្កេតបានធ្វើការស្តាប់ចម្លើយជនរងគ្រោះចំនួន ០៣ រូប ក្នុងចំណោមជនរងគ្រោះ ០៥ រូប ដែលមានលើកឡើងក្នុងឯកសារចុះថ្ងៃ ០៦ មករា ២០១០ របស់ ក.ស.ព.៖ [redacted] (D22/101) [redacted] (D22/103) និង [redacted] (D22/102)។

00428849

លេខ/ No: D 250/3/3

## អាស្រ័យហេតុនេះ

**សម្រេច** បដិសេធសំណើសុំរបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៩ចំពោះ ចំណុចដែលសំណើសុំនេះស្វែងរកការពង្រីកវិសាលភាពនៃការស៊ើបសួរ ដែលកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

**សម្រេច** បដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ ថ្ងៃ ៦ មករា ២០១០ របស់ ក.ស.ព. ខណៈដែលសំណើសុំនេះទាក់ទងទៅនឹងអង្គហេតុ ដែលមិនថិតក្នុងវិសាលភាពនៃការស៊ើបសួរ។

**សម្រេច** បដិសេធសំណើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខណៈដែលសំណើសុំនេះបាន លើកឡើងអំពីបញ្ហាតែមួយដូចគ្នាទៅនឹងអ្វី ដែលសំណើសុំរបស់ ក.ស.ព បានលើកឡើង និងដែល ការលើកឡើងនេះមិនថិតនៅក្នុងវិសាលភាពនៃការស៊ើបសួរ។

**សម្រេច** ការកំណត់អំពីក្រុមជនរងគ្រោះ ដែលត្រូវប្រើប្រាស់ក្នុងបទល្មើសឧក្រិដ្ឋកម្ម ប្រល័យពូជសាសន៍ នឹងត្រូវបានសម្រេចនៅក្នុងដីកាដំណោះស្រាយ។

**សម្រេច** បញ្ជាក់ថាសំណើសុំរបស់សហព្រះរាជអាជ្ញាអាចទទួលយកបាន ចំពោះចំណុច ដែលថាសំណើនេះសុំឲ្យមានការបំពេញកិច្ចស៊ើបសួរ ដែលអាចចូលរួមដល់ការបង្ហាញការពិតលើ បញ្ហាដែលទាក់ទងនឹងទំរង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលអាចត្រូវអនុវត្តចំពោះជនត្រូវ ចោទ និង/ឬ ធាតុផ្សំយុត្តាធិការនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១០

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

យូ ប៊ុនឡេង

**Marcel LEMONDE**